# សេចក្ដីអំពាវនាវ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ ចំពោះប្រជាពលរដ្ឋខ្មែរដែលរងទុក្ខវេទនាដោយរបបកម្ពុជាប្រជាធិបតេយ្យ (ខ្មែរក្រហម) សូមដាក់ពាក្យប្ដឹងទៅតុលាការចំរុះអន្តរជាតិកាត់ទោសខ្មែរក្រហម ដែលនឹងកើតមានក្នុងពេលខាងមុខនេះ

web site: hoksavann.org

ថ្ងៃទី១២ ឧសភា ២០០៦

សោកនាដកម្មរបស់ប្រជាពលរដ្ឋខ្មែរ ដែលកើតមានក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ខ្មែរក្រហម) អំឡុងឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ជាអំពើគួរឲ្យរន្ធត់ ដែលមិនធ្លាប់កើតមានក្នុងប្រវត្តិសាស្ត្រពិភពលោក ជាពិសេសប្រវត្តិសាស្ត្រខ្មែរ។ គ្រប់គ្រួសារខ្មែរបានទទួលរងទុក្ខវេទនាដោយរបបនេះ គ្រាន់តែមានទម្ងន់ទុក្ខច្រើនជាងគ្នាប៉ុណ្ណោះ ។ ការស្លាប់ព្រាត់ប្រាស់ក្រុមគ្រួសារបងប្អូនកូនចៅម្ដាយឪពុកប្រពន្ធពិការផ្លូវកាយវិបត្តិផ្លូវចិត្ត មានទំហំដ៏ធំធេង ដែលភាសាមនុស្សពុំអាចពណ៌នាបានឡើយ ។ ពុទ្ធសាសនិកជនខ្មែរដឹងគ្រប់គ្នាហើយថា ព្រះពុទ្ធហាមមិនឲ្យមនុស្សចងពៀរគ្នា ប៉ុន្តែព្រះអង្គមិនបានហាមឲ្យមនុស្សរកយុត្តិធម៌តាមផ្លូវច្បាប់ដែរ ។ តួយ៉ាងដូចព្រះសង្ឃមានជម្លោះនឹងគ្នា ព្រះអង្គអនុញ្ញាតឲ្យកាត់សេចក្ដីរកយុត្តិធម៌តាមធម៌វិន័យ ដែលជាច្បាប់ព្រះពុទ្ធសាសនាដែរ ។ ដូចគ្នានេះដែរ ពួកខ្មែរក្រហមនិងជនបរទេស ដែលពាក់ព័ន្ធនឹងការសម្លាប់ប្រជាពលរដ្ឋខ្មែររាប់លាននាក់ មិនត្រឹមតែខុសនឹងច្បាប់ខ្មែរ, ច្បាប់ព្រះពុទ្ធសាសនាប៉ុណ្ណោះទេ គឺខុសនឹងច្បាប់អង្គការសហប្រជាជាតិផង ។ ដូចនេះដើម្បីជាមេរៀន ជាគំរូអាក្រក់ កុំឲ្យមនុស្សក្រោយទៀតយកតម្រាប់តាម និងដើម្បីរកយុត្តិធម៌ជូនអ្នករងគ្រោះ ចាំបាច់ត្រូវតែមានការកាត់ទោស ។ ហេតុនេះ សូមអំពាវនាវដល់ជនជាតិខ្មែរ ក្នុងប្រទេសនិងក្រៅប្រទេស ដែលទទួលទារុណកម្មដោយអំពើឧក្រិដ្ឋកម្ម របស់ខ្មែរក្រហមនិងជនបរទេស ដែលទាក់ទងនឹងការកាប់សម្លាប់នេះ សូមដាក់ពាក្យប្ដឹងទៅតុលាការចំរុះអន្តរជាតិកាត់ទោសខ្មែរក្រហម ដែលមានទីចាត់ការនៅភ្នំពេញប្រទេសកម្ពុជា ហើយដែលចៅក្រមចំរុះបំរុងធ្វើការស៊ើបអង្កេ

ត ក្នុងពេលឆាប់ៗនេះ មុននឹងធ្វើសវនាការ ។

១- ពាក្យបណ្ដឹងត្រូវធ្វើជាលាយលក្ខណ៍អក្សរ ដោយបញ្ជាក់អំពីការធ្វើទារុណកម្ម នៅទីកន្លែងណា នៅឆ្នាំណា ខ្មែរក្រហមថ្នាក់ណា ខ្មែរក្រហមឈ្មោះអ្វី បើស្គាល់ឈ្មោះ ។ មួយទៀត ក្រៅពីគ្រួសារផ្ទាល់ បើឃើញខ្មែរដទៃទៀត ត្រូវខ្មែរក្រហមធ្វើទារុណកម្មកាប់សម្លាប់ បង្ខំឲ្យធ្វើការជាទម្ងន់ បង្អត់អាហារ ក៏សូមសរសេរភ្ជាប់មកជាមួយដែរ ដើម្បីជាសាក្សីនៃអំពើឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម ។

២- ឧក្រិដ្ឋកម្មមកលើព្រះពុទ្ធសាសនា ។ សូមប្រជាពលរដ្ឋខ្មែរ ដែលបានឃើញខ្មែរក្រហមបំផ្លាញព្រះពុទ្ធសាសនា ដែលក្នុងនោះមានការធ្វើគតព្រះសង្ឃ បង្ខំព្រះសង្ឃឲ្យសឹក វាយកំទេចវត្តអារាម ព្រះវិហារ ព្រះពុទ្ធរូប បំផ្លាញគម្ពីរក្បួនច្បាប់ព្រះពុទ្ធសាសនាជាដើម សូមសរសេរភ្ជាប់មកជាមួយ ។

៣- បើប្រជាពលរដ្ឋខ្មែរ ឃើញជនបរទេសធ្វើការជាមួយពួកខ្មែរក្រហម ក្នុងអំឡុងពេលនេះ ក៏សូមសរសេរឈ្មោះជនជាតិនោះ ដើម្បីរកអ្នកនៅពីក្រោយខ្មែរក្រហម ក្នុងអំពើកាប់សម្លាប់នោះ ។ គេដឹងគ្រប់ៗគ្នាហើយថា សាធារណរដ្ឋប្រជាមានិតចិន (ចិនកុម្មុយនិស្ត) នៅធ្វើការជាមួយខ្មែរក្រហម មានទីប្រឹក្សាគ្រប់ផ្នែកនៅពេ-លនោះ ។ ជាមួយគ្នានោះ វៀតណាមដែលមានទំនាស់ជាមួយខ្មែរក្រហមយ៉ាងខ្លាំងក្លានៅពេលនោះដែរ ។

ពាក្យបណ្ដឹងរបស់ប្រជាពលរដ្ឋខ្មែរតំណាងគ្រួសារអ្នករងគ្រោះ មានតម្លៃណាស់ ព្រោះបានជាភស្តុតាងនិងជាសាក្សីបន្ថែមទៀត សំរាប់ចៅក្រមស៊ើបអង្កេតយកទៅពិចារណា ដើម្បីធ្វើការចោទប្រកាន់ ទោះបីតុលាការកម្រិតពិរុទ្ធជន គឺកាត់ទោសចំពោះតែកម្មាភិបាលជាន់ខ្ពស់ក៏ដោយ ក៏ជនឧក្រិដ្ឋទាំងថ្នាក់ទាបទាំងថ្នាក់ខ្ពស់ដទៃទៀត ជាពិសេសជនដែលធ្វើឲ្យខ្មែរក្រហមឈ្នះ និងជនបរទេសដែលនៅពីក្រោយខ្មែរក្រហម ពុំអាចរួចខ្លួនអំពីអំពើឧក្រិដ្ឋរបស់ខ្លួនឡើយ ។

សូមប្រជាពលរដ្ឋខ្មែរ កុំភ្លេចដាក់ពាក្យបណ្ដឹងទៅតុលាការចំរុះអន្តរជាតិនេះ ទោះបីមិនទាន់ទាក់ចិត្តទាំងស្រុងថា តុលាការនេះអាចរកយុត្តិធម៌ប្រគេននិងជូនអ្នករងគ្រោះក៏ដោយ ក៏ចាត់ទុកថាបានបំពេញកាតព្វកិច្ចរបស់ខ្លួន ដើម្បីតបគុណាប្រគេននិងជូនព្រះសង្ឃ និងក្រុមគ្រួសាររបស់ខ្លួន ដែលត្រូវជនឧក្រិដ្ឋធ្វើគត និងសម្លាប់យ៉ាងព្រៃផ្សៃ ។៚

❑ ❑

❑